ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៤-០៩-៧១៥ (ធ.ក)

# ប្រកាស

## ស្តីពី

## ការបង្កើតមុខតំណែងមន្ត្រីបច្ចេកទេសជាន់ខ្ពស់ធនាគារជាតិនៃកម្ពុជា

### ទេសាភិបាលធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មមាត្រា១៤ និងមាត្រា៥៧ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៨/៥២៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ២០០៨ ស្តីពីការតែងតាំងឯកឧត្តម **ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា មានឋានៈស្មើទេសរដ្ឋមន្ត្រី
- យោងតាមលក្ខន្តិកៈដោយឡែករបស់មន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជា
- យោងតាមស្មារតីអង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ២០០៩

### ស ម្រេ ច

**ប្រការ ១.-** បង្កើតមុខតំណែងមន្ត្រីបច្ចេកទេសជាន់ខ្ពស់ធនាគារជាតិនៃកម្ពុជា ដែលមានងារជា**អធិការ** ហើយត្រូវបានរៀបបញ្ចូលទៅក្នុងក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់ធនាគារជាតិនៃកម្ពុជា ។

**ប្រការ ២.-** អធិការត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់នាយកដ្ឋាន-អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា ។

**ប្រការ ៣.-** អធិការមិនមែនជាមន្ត្រីដឹកនាំគ្រប់គ្រង ប៉ុន្តែជាមន្ត្រីបច្ចេកទេសជាន់ខ្ពស់បំរើការងារបច្ចេកទេសតាមជំនាញផ្សេងៗដូចជា ការងារអធិការកិច្ច សវនកម្មផ្ទៃក្នុង ជំនាញគណនេយ្យ ជំនាញច្បាប់ ព័ត៌មានវិទ្យា ត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ស្រាវជ្រាវ សិក្សាទីផ្សារហិរញ្ញវត្ថុ បញ្ហានិងគ្រប់គ្រងម៉ាស៊ីន និងឧបករណ៍ទំនើប ។

Downloaded from http://www.khmerlaws.com

**ប្រការ ៤.-** មុខតំណែងអធិការ រួមមាន ៦ ថ្នាក់ ៖

- អធិការ ថ្នាក់លេខ ១ មានឋានៈស្មើអគ្គនាយក
- អធិការ ថ្នាក់លេខ ២ មានឋានៈស្មើអគ្គនាយករង
- អធិការ ថ្នាក់លេខ ៣ មានឋានៈស្មើប្រធាននាយកដ្ឋាន
- អធិការ ថ្នាក់លេខ ៤ មានឋានៈស្មើអនុប្រធាននាយកដ្ឋាន
- អធិការ ថ្នាក់លេខ ៥ មានឋានៈស្មើប្រធានការិយាល័យ
- អធិការ ថ្នាក់លេខ ៦ មានឋានៈស្មើអនុប្រធានការិយាល័យ ។

**ប្រការ ៥.-** ការជ្រើសរើសចូលក្នុងមុខតំណែងអធិការ ត្រូវធ្វើឡើងតាមរយៈការប្រឡងប្រជែងផ្ទៃក្នុងធនាគារជាតិនៃកម្ពុជា ក្នុងចំណោមបេក្ខជនជាមន្ត្រីបុគ្គលិកពេញសិទ្ធិគ្រប់ប្រភេទក្របខ័ណ្ឌ ដែលមានសញ្ញាបត្រទាបបំផុតស្មើនឹងបរិញ្ញាបត្រជាន់ខ្ពស់ ឬ អនុបណ្ឌិត ឬសញ្ញាបត្រដែលមានតម្លៃស្មើ ។

**ប្រការ ៦.-** មន្ត្រីបុគ្គលិកដែលបានប្រឡងប្រជែងជាប់ជាស្ថាពរពុំចាំបាច់ឆ្លងកាត់ការធ្វើកម្មសិក្សាឡើយ ។ មន្ត្រីបុគ្គលិកទាំងនេះ ត្រូវបានតែងតាំងជា**អធិការថ្នាក់លេខ ៦** ។

**ប្រការ ៧.-** អធិការមិនអាចត្រូវបានអនុញ្ញាតឱ្យផ្ទេរទៅបំរើការងារនៅក្រសួង និងស្ថាប័នផ្សេងឡើយ ។

**ប្រការ ៨.-** អធិការត្រូវបានរៀបចំដំឡើងថ្នាក់ទៅតាមលក្ខខណ្ឌ ដូចខាងក្រោម ៖

- អធិការ ថ្នាក់លេខ៦ ឡើងថ្នាក់លេខ៥ មានរយៈពេល ២ឆ្នាំ
- អធិការ ថ្នាក់លេខ៥ ឡើងថ្នាក់លេខ៤ មានរយៈពេល ៣ឆ្នាំ
- អធិការ ថ្នាក់លេខ៤ ឡើងថ្នាក់លេខ៣ មានរយៈពេល ៣ឆ្នាំ
- អធិការ ថ្នាក់លេខ៣ ឡើងថ្នាក់លេខ២ មានរយៈពេល ៥ឆ្នាំ
- អធិការ ថ្នាក់លេខ២ ឡើងថ្នាក់លេខ១ មានរយៈពេល ៥ឆ្នាំ ។

លក្ខណៈសម្បត្តិជាមូលដ្ឋាន ដែលត្រូវពិនិត្យសម្រាប់ដំឡើងថ្នាក់ ដូចមានចែងក្នុងប្រការ ១៣ នៃលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌ មន្ត្រីជាន់ខ្ពស់ធនាគារជាតិនៃកម្ពុជា ។

**ប្រការ ៩.-** ថ្នាក់ និងសន្ទស្សន៍សម្រាប់ អធិការ ត្រូវបានកំណត់ដូចខាងក្រោម ៖

- អធិការ ថ្នាក់លេខ ១ សន្ទស្សន៍ ៥៥០
- អធិការ ថ្នាក់លេខ ២ សន្ទស្សន៍ ៤៨៧
- អធិការ ថ្នាក់លេខ ៣ សន្ទស្សន៍ ៤៦៧
- អធិការ ថ្នាក់លេខ ៤ សន្ទស្សន៍ ៤២៥
- អធិការ ថ្នាក់លេខ ៥ សន្ទស្សន៍ ៣៩០
- អធិការ ថ្នាក់លេខ ៦ សន្ទស្សន៍ ៣៤០ ។

Downloaded from http://www.khmerlaws.com

**ប្រការ ១០.-** តម្លៃឯកតានៃសន្ទស្សន៍សម្រាប់អនុវត្តក្នុងតារាងប្រាក់បៀវត្ស ត្រូវបានកំណត់និងកែសម្រួលតាមគោលការណ៍កំណត់របស់ធនាគារជាតិនៃកម្ពុជា ។

**ប្រការ ១១.-** អធិការត្រូវទទួលបាន**ប្រាក់បំណាច់មុខងារកម្រិតទី ៣** តាមមុខតំណែងដូចមានចែងក្នុងប្រកាស លេខ ធ៨.០៥-១២៨ ប្រក ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៥ ស្តីពីការកំណត់ប្រាក់បំណាច់មុខងាររបស់មន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជា និងត្រូវទទួលបានប្រាក់ឧបត្ថម្ភផ្សេងៗទៀត តាមគោលការណ៍កំណត់របស់ធនាគារជាតិនៃកម្ពុជា ។

**ប្រការ ១២.-** អធិការត្រូវអនុវត្តតាមបទប្បញ្ញត្តិផ្សេងៗ ដូចមានចែងនៅក្នុងជំពូកទី៧នៃប្រកាសស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីជាន់ខ្ពស់ធនាគារជាតិនៃកម្ពុជា ។

**ប្រការ ១៣.-** រាល់ប្រកាស ឬលិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ១៤.-** អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន-អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ១៥.-** ប្រកាសនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កញ្ញា ឆ្នាំ ២០០៥

ជា-ចាន់តូ

**កន្លែងទទួល**

- ដូចប្រការ ១៤

**" ដើម្បីអនុវត្ត "**

- ឯកសារ-កាលប្បវត្តិ

**ចម្លងជូន**

- គ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី

" ដើម្បីជូនជ្រាបជាព័ត៌មាន "

- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី

" ដើម្បីចុះផ្សាយក្នុងរាជកិច្ច "

Downloaded from http://www.khmerlaws.com